# សិវិជាតក

(ព្រះបាទសិវិពោធិសត្វបរិច្ចាគភ្នែកជាទាន)



## ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ
## ជាតក វីសតិនិបាត បិដកលេខ ៦0 ទំព័រ ៧៤


**ដោយ ខេមរ អភិធម្មាវតារ**


**ព.ស. ២៥៦១**

# សិរិជាតក

*ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអសទិសទាន ត្រាស់ធម្មទេសនានេះ មានពាក្យថា* **ន វេ អបស្សាំ ទេវលោកំ** *ដូចនេះជាដើម ។*

*រឿងរ៉ាវជាបច្ចុប្បន្ននិទាននោះ បានពោលពិស្តារហើយក្នុង**សិរិជាតក** ក្នុង**អដ្ឋកនិបាត**នោះឯង ។*

*ក្នុងកាលនោះ ព្រះបាទ**បសេនទិកោសល** ទ្រង់ថ្វាយបរិក្ខារគ្រប់យ៉ាង ក្នុងថ្ងៃទី ៧ ទូលសូមនូវការអនុមោទនា ។ ព្រះសាស្តាមិនបានត្រាស់អ្វីឡើយ ស្តេចទៅកាន់វិហារ ។ ព្រះរាជាទ្រង់យាងទៅកាន់វិហារកក្នុងវេលានៃភោជនគឺបុគ្គលគប្បីបរិភោគក្នុងវេលាព្រឹក (ក្នុងវេលាអាហារពេលព្រឹក) ហើយត្រាស់សួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុអ្វី ព្រះអង្គទើបមិនធ្វើការអនុមោទនា ? ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ ព្រោះបរិសទ្យមិនបរិសុទ្ធ ហើយទ្រង់សម្តែងព្រះធម្មទេសនាដោយព្រះគាថាថា* **ន វេ កទរិយា ទេវលោកំ វជន្តិ**[១] **បុគ្គលកំណាញ់ស្វិតស្វាញមិនបានទៅកាន់ទេវលោកទេ** *ជាដើម ។ ព្រះរាជាទ្រង់ជ្រះថ្លាបានបូជាព្រះតថាគតដោយសំពត់ឧត្តរាសង្គៈ (សំពត់ដណ្តប់) ដែលជាសីវេយ្យកពស្ត្រមានតម្លៃ ១ សែន ហើយស្តេចត្រឡប់ ទៅព្រះនគរ ។*

---

*១. ខុទ្ទកនិកាយ ធម្មបទ លោកវគ្គ បិដកលេខ ៥២ ទំព័រ ៥៩ ។*

ក្នុងថ្ងៃស្អែក ភិក្ខុទាំងឡាយសន្ទនាគ្នា ក្នុងសាលាធម្មសភាថា ម្នាលអាវុសោទាំងឡាយ ព្រះរាជាក្នុងដែនកោសល ទ្រង់ថ្វាយ**អសទិសទាន** ហើយនៅមិនឆ្អែតស្កប់ស្កល់ ដោយទានសូម្បីមានសភាពដូច្នោះ កាលព្រះ ទសពលទ្រង់សម្តែងធម៌ហើយ បានថ្វាយសំពត់សីវេយ្យកៈដែលមានតម្លៃ ១ សែនទៀត ម្នាលអាវុសោទាំងឡាយ រហូតវេលាដែលទ្រង់ថ្វាយទាននៅមិនឆ្អែតស្កប់ស្កល់ព្រះទ័យឡើយ ។ ព្រះសាស្តាស្តេចមកហើយ ត្រាស់សួរថា ម្នាល ភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកសន្ទនាគ្នាដោយរឿងអ្វី ? កាលភិក្ខុទាំងនោះក្រាបទូលហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដែលឈ្មោះថាពាហិរភណ្ឌ គឺជាទានដែលបុគ្គលឲ្យហើយដោយល្អ បោរាណកបណ្ឌិតទាំងឡាយធ្វើជម្ពូទ្វីបទាំងអស់ឲ្យជាទីទួល ហើយឲ្យទានបរិច្ចាគទ្រព្យ ៦ សែនរាល់ ៗ ថ្ងៃ នៅមិនឆ្អែតស្កប់ស្កល់ដោយពាហិរទានឡើយ ហើយត្រាស់ទៀតថា អ្នកឲ្យរបស់ដែលជាទីស្រឡាញ់ រមែងបានរបស់ដែលជាទីស្រឡាញ់ ដូច្នេះ បណ្ឌិតទាំងឡាយទើបបានឆ្កៀលហើយនូវភ្នែកទាំង ២ ឲ្យដល់យាចកដែលមកដល់ចំពោះមុខ ហើយទ្រង់នាំអតីតនិទានមកសម្តែងថា

ក្នុងអតីតកាល ព្រះបាទ**សិវិមហារាជ** សោយរាជ្យសម្បត្តិក្នុង**អរិដ្ឋបុរនគរ** ក្នុងដែន**សិវិរដ្ឋ** ព្រះមហាសត្វទ្រង់កើតជាព្រះឱរស របស់ព្រះបាទសិវិមហារាជនោះ ។ ព្រះញាតិវង្សទាំងឡាយ បានថ្វាយព្រះនាមថា **សិវិកុមារ** ។ ព្រះរាជ-

កុមារចម្រើនវ័យហើយ បានទៅកាន់នគរតក្កសិលា សិក្សាសិល្បសាស្ត្រចប់សព្វគ្រប់ហើយ ត្រឡប់មកសម្ដែងសិល្បសាស្ត្រថ្វាយព្រះរាជបិតាទត ហើយបានទទួលព្រះរាជទានយសជាមហាឧបរាជ ក្នុងវេលាបន្តបន្ទាប់មក កាលព្រះរាជបិតាទ្រង់ចូលទីវង្គតហើយ ក៏បានជាព្រះរាជា ទ្រង់លះការលុះក្នុងអគតិ មិនញ៉ាំងនូវទសរាជធម៌ឲ្យកម្រើក សោយរាជ្យសម្បត្តិប្រកបដោយធម៌ ទ្រង់បានឲ្យសាងសាលទានទុក ៦ កន្លែង គឺត្រង់ទ្វារព្រះនគរ ៤ កន្លែង កណ្ដាលព្រះនគរ ១ កន្លែង និងត្រង់ទ្វារព្រះរាជនិវេសន៍ ១ កន្លែង ហើយទ្រង់ញ៉ាំងមហាទានឲ្យប្រព្រឹត្តទៅ ដោយទ្រង់បរិច្ចាគទ្រព្យ ៦ សែន រាល់ ៗ ថ្ងៃ ។ ក្នុងថ្ងៃអដ្ឋមី ចាតុទ្ទសី បន្នរសី គឺថ្ងៃ ៨, ១៤, ១៥ ព្រះរាជាស្ដេចយាងទៅកាន់រោងទាន ទ្រង់ត្រួតពិនិត្យមើលការឲ្យទាន ជាព្រះរាជករណីយកិច្ចជាប្រចាំ ។

គ្រាមួយ ជាថ្ងៃពេញបូរមី មានតិថី ១៥ កើត ក្នុងពេលព្រឹក ព្រះបាទសិវិប្រថាប់លើរាជបល្ល័ង្កខាងក្រោមសមុស្សិតសេ្វតច្ឆត្រ ទ្រង់ត្រិះរិះដល់ទានដែលព្រះអង្គបានបរិច្ចាគ មិនបានឃើញពាហិរវត្ថុណាមួយដែលព្រះអង្គនៅធ្លាប់ឲ្យឡើយ ទើបទ្រង់ព្រះចិន្តាថា ពាហិរវត្ថុដែលឈ្មោះថា យើងនៅមិនបានបរិច្ចាគមិនមាន ពាហិរទាននៅមិនបានញ៉ាំងយើងឲ្យត្រេកអរឡើយ យើងប្រាថ្នានឹងឲ្យអជ្ឈត្តិកទាន, ឱហ្ន៎ ! ក្នុងថ្ងៃនេះ វេលាដែលយើងទៅរោងទាន យាចកណានីមួយប៉ុណ្ណោះ កុំសូមពាហិរវត្ថុឡើយ គប្បីកាន់យកនូវឈ្មោះនៃអជ្ឈត្តិកទាន

ចុះ, ពិតមែន ប្រសិនបើអ្នកណានីមួយ គប្បីកាន់យកនូវឈ្មោះនៃសាច់បេះដូង របស់យើងសោត យើងនឹងពុះទ្រូងដោយច្បូក នាំយកបេះដូងដែលជាទីហូរ ចេញនៃដំណក់ឈាមហើយឲ្យ បីដូចជា កាលដកឡើងនូវបទុមជាតិទាំងដើម ចេញអំពីទឹកដ៏ថ្លាដូច្នោះ បើអ្នកណាមួយ ចេញមាត់សូមសាច់ក្នុងសរីរៈរបស់ យើង យើងនឹងពន្ធះសាច់ក្នុងសរីរៈហើយឲ្យ បីដូចជាកាលធូតនូវចន្ទន៍ក្រហម ដោយសត្រាសម្រាប់ធូតដូច្នោះ ប្រសិនបើអ្នកណាសូមលោហិត យើងនឹងចូល ទៅក្នុងយន្តមុខ (អាវុធ) ញ៉ាំងភោជនដែលមនុស្សនាំចូលទៅហើយឲ្យពេញ ហើយឲ្យនូវលោហិត ។ ម្យ៉ាងទៀត ប្រសិនបើអ្នកណាមួយនិយាយនឹងយើងថា ការងារក្នុងផ្ទះរបស់ខ្ញុំមិនប្រព្រឹត្តទៅ ព្រះអង្គចូរធ្វើនូវការងារនៃទាសៈ ក្នុងផ្ទះ របស់ខ្ញុំ ដូច្នេះ យើងនឹងលះការតែងខ្លួនជាក្សត្រ ធ្វើខ្លួនឲ្យតាំងនៅក្នុងចំណែក ខាងក្រៅតំណែង ហើយប្រកាសខ្លួនធ្វើការងាររបស់ទាសៈ ។ បើអ្នកណាសូម កែវភ្នែករបស់យើង យើងឆ្កៀលកែវភ្នែកទាំងគូឲ្យ ហាក់បីដូចជាកាលនាំចេញ នូវសាច់ត្នោត ដូច្នោះ ។ ព្រះរាជាទ្រង់ត្រិះរិះតទៅទៀតថា

**យំកិញ្ចិ មានុសំ ទានំ អទិន្នំ មេ ន វិជ្ជតិ**
**យោបិ យាចេយ្យ មំ ចក្ខុំ ទទេយ្យំ អវិកម្បិតោ**[១] ។

១. ខុទ្ទកនិកាយ ចរិយាបិដក សិវិរាជចរិយា បិដកលេខ ៧៧ ទំព័រ ២៥០ ។

ទានណាមួយជារបស់មនុស្ស ទាននោះ គឺអញមិនដែលឱ្យហើយ មិនមានឡើយ បើមានយាចកណាមកសូមភ្នែកអញ អញនឹងមិនញាប់ញ័រ ត្រូវតែឱ្យ (ដល់យាចកនោះ) ។

ដូចនេះហើយ ទ្រង់ស្រង់ដោយទឹកក្រអូប ១៦ ក្អម ទ្រង់ប្រដាប់តាក់តែងហើយដោយគ្រឿងអលង្ការទាំងពួង សោយព្រះក្រយាហារ ដែលមានរសដ៏ប្រណីតផ្សេងៗ ហើយស្តេចប្រថាប់លើដំរីមង្គល ដែលប្រដាប់តាក់តែងហើយ ស្តេចបានទៅកាន់រោងទាន ។

សក្កទេវរាជទ្រង់ជ្រាបអធ្យាស្រ័យរបស់ព្រះមហាសត្វ ទើបត្រិះរិះថា ថ្ងៃនេះ ព្រះបាទសិវិរាជទ្រង់ត្រិះរិះថា នឹងធ្មៀលព្រះនេត្រព្រះរាជទានដល់យាចក ដែលមកដល់ចំពោះមុខ ព្រះអង្គនឹងអាចព្រះរាជទាន ឬមិនអាច ? កាលនឹងទ្រង់សាកល្បងព្រះបាទសិវិ ទើបទ្រង់ក្លែងភេទជាព្រាហ្មណ៍ចាស់ជរាមានភ្នែកងងឹត ក្នុងវេលាព្រះរាជាស្តេចទៅកាន់រោងទាន បានឈរក្នុងទីខ្ពស់មួយ លាតនូវដៃថ្វាយជយមង្គលដល់ព្រះរាជា ។ ព្រះរាជាឲ្យបញ្ឈប់ដំរីចំពោះមុខព្រាហ្មណ៍នោះ ហើយត្រាស់សួរថា ម្នាលព្រាហ្មណ៍ លោកនិយាយអ្វី ? លំដាប់នោះ សក្កទេវរាជត្រាស់ថា បពិត្រមហារាជ លោកសន្និវាសទាំងអស់ផ្សាយទៅដោយកិត្តិសព្ទ ដែលទៅហើយក្នុងចំណែកខាងលើ អស់កាលជានិច្ចព្រោះអាស្រ័យអធ្យាស្រ័យ បង្អោនទៅក្នុងទានរបស់ព្រះអង្គ ចំណែកខ្ញុំព្រះ

ករុណាជាមនុស្សខ្វាក់ ព្រះអង្គមានព្រះនេត្រទាំងពីរ ដូចនេះហើយ កាលនឹងទូលសុំកែវភ្នែក ទើបត្រាស់ព្រះគាថាទី ១ ថា

ទូរេ អបស្សំ ថេរោវ, ចក្ខុំ យាចិតុមាគតោ;
ឯកនេត្តា ភវិស្សាម, ចក្ខុំ មេ ទេហិ យាចិតោ។

**ខ្ញុំព្រះអង្គជាបុគ្គលចាស់ជរា មើលមិនឃើញឆ្ងាយ មកដើម្បីសុំនូវព្រះនេត្រ ខ្ញុំព្រះអង្គជាអ្នកមានភ្នែកម្ខាង កាលបើខ្ញុំសុំហើយ សូមព្រះអង្គប្រទាននូវព្រះនេត្រដល់ខ្ញុំព្រះអង្គ ។**

បណ្ដាបទទាំងនោះ បទថា **ទូរេ** សេចក្ដីថា នៅឆ្ងាយអំពីទីនេះ ។ បទថា **ថេរោ** សេចក្ដីថា ជាមនុស្សចាស់ អ្នកចូលដល់សេចក្ដីគ្រាំគ្រាព្រោះជរា ។ បទថា **ឯកនេត្តា** សេចក្ដីថា សូមព្រះអង្គទ្រង់ព្រះរាជទានព្រះនេត្រ ១ ដល់ខ្ញុំ ខ្ញុំព្រះករុណាជាអ្នកមានភ្នែកម្ខាង នឹងមានទាំងពីរខាងបានដោយវិធីនេះ ។

ព្រះមហាសត្វទ្រង់ស្ដាប់ពាក្យនោះហើយ បានត្រិះរិះថា យើងអង្គុយគិតលើប្រាសាទ ឥឡូវមកទាន់ពេលតែម្ដង នេះជាលាភរបស់យើង មនោរថរបស់យើង នឹងដល់ទីបំផុតក្នុងថ្ងៃនេះពិត យើងនឹងបរិច្ចាគទានដែលមិនធ្លាប់បរិច្ចាគក្នុងកាលមុន ហើយទ្រង់មានព្រះហឫទ័យរីករាយសោមនស្ស ត្រាស់ព្រះគាថាទី ២ ថា

កោជានុសិដ្ឋោ ឥធ មាគតោសិ,
វនិព្ពក ចក្ខុបថានិ យាចិតុំ;
សុទុច្ចជំ យាចសិ ឧត្តមង្គំ, យ
មាហុ នេត្តំ បុរិសេន'ទុច្ចជំ។

*នែស្ទម អ្នកណាប្រាប់អ្នក ទើបអ្នកមកក្នុងទីនេះ បម្រុងសុំនូវភ្នែកទាំងឡាយ ជនទាំងឡាយពោលនូវភ្នែកណា ថាជារបស់ដែលបុរសលះបានដោយក្រ អ្នកសុំនូវភ្នែក ជាអវយវៈដ៏ខ្ពង់ខ្ពស់នោះ ដែលគេលះបានដោយក្រក្រៃលែង ។*

*ក្នុងព្រះគាថានោះ ព្រះបាទសិវិរាជ ត្រាស់ហៅសក្កទេវរាជថា វនិព្វកៈ ។ បទថា ចក្ខុបថានិ នេះ ជាឈ្មោះនៃចក្ខុទាំងពីរខាង ។ បទថា យមាហុ សេចក្ដីថាបណ្ឌិតទាំងឡាយពោលដួងភ្នែកណាដែលបុរសលះបានដោយក្រ ។*

*ខាងមុខអំពីនេះទៅ គប្បីជ្រាបសម្ពន្ធគាថាផាយៗ ដោយន័យដែលមកហើយក្នុងព្រះបាលីដូចតទៅ ព្រាហ្មណ៍ទូលតបថា*

យមាហុ ទេវេសុ សុជម្បតីតិ,
មឃវាតិ នំ អាហុ មនុស្សលោកេ;
តេជានុសិដ្ឋោ ឥធ មាគតោស្មិ,
វនិព្ពកោ ចក្ខុបថានិ យាចិតុំ។

*ពួកទេវតាបានពោលនូវទេវតាវិសេសណា ថាសុជម្បតិ ក្នុងទេវលោក ពួកជនបានពោលនូវទេវតាវិសេសនោះថាមឃវៈ ក្នុងមនុស្សលោក ខ្ញុំជាស្នួមដែលទេវតាវិសេសនោះប្រាប់ ទើបមកក្នុងទីនេះបម្រុងសុំព្រះនេត្រទាំងឡាយ ។*

វនិព្វតោ មយ្ហំ វនឹ អនុត្តរំ,
ទទាហិ តេ ចក្ខុបថានិ យាចិតោ;
ទទាហិ មេ ចក្ខុបថំ អនុត្តរំ,
យមាហុ នេត្តំ បុរិសេន ទុច្ចជំ។

*ខ្ញុំជាស្នួម ការសូមជាកិច្ចឧត្តម របស់ខ្ញុំ កាលបើខ្ញុំសូមព្រះនេត្រទាំងឡាយ សូមព្រះអង្គប្រទាន ពួកជនបានពោលនូវភ្នែកណា ថាជារបស់ដែលបុរសលះបានដោយក្រ សូមព្រះអង្គប្រទាននូវព្រះនេត្រដ៏ប្រសើរនោះដល់ខ្ញុំព្រះអង្គ ។*

*ព្រះបាទសិវិត្រាស់តបថា*

យេន អត្ថេន អាគច្ឆិ, យមត្ថមភិបត្ថយំ;
តេ តេ ឥជ្ឈន្តុ សង្កប្បា, លភ ចក្ខូនិ ព្រាហ្មណា។

ខ្លួនអ្នកមកដោយប្រយោជន៍ណា ប្រាថ្នានូវប្រយោជន៍ណា ម្នាលព្រាហ្មណ៍ អ្នកចូរបាននូវភ្នែកទាំងឡាយ ។

យំ តំ តេ យាចមានស្ស,
ឧភយានិ ទទាមហំ;
ស ចក្ខុមា គច្ឆ ជនស្ស បេក្ខតោ,
យទិច្ឆសេ ត្វំ តទតេ សមិជ្ឈតុ។

កាលបើ អ្នកសូមភ្នែកមួយ យើងនឹងឲ្យភ្នែកទាំងពីរ កាលជនកំពុងមើល សូមអ្នកនោះជា បុគ្គលមានភ្នែកទៅចុះ អ្នកប្រាថ្នានូវរបស់ណា របស់នោះចូរសម្រេចដល់អ្នក ។

បណ្តាបទទាំងនោះ បទថា **វនិព្វតោ** បានដល់ យាចក ។ បទថា **វនិ** សេចក្តីថា ការសូម ។ បទថា **តេ តេ** សេចក្តីថា សេចក្តីត្រិះរិះដើម្បីត្រូវការរបស់ នោះរបស់លោកចូរសម្រេច ។ បទថា **ស ចក្ខុមា** សេចក្តីថា អ្នកនោះចូរជាអ្នកមានចក្ខុដោយចក្ខុរបស់យើងទៅចុះ ។ បទថា **យទិច្ឆសេ ត្វំ តទតេ សមិជ្ឈតុ** សេចក្តីថា លោកប្រាថ្នា វត្ថុណាអំពីយើង សូមវត្ថុនោះចូរសម្រេចដល់លោកចុះ ។

ព្រះរាជាត្រាស់ត្រឹមតែប៉ុណ្ណោះ ហើយទ្រង់ត្រិះរិះថា ការដែលយើងនឹងឆ្កៀលភ្នែកឲ្យដល់ព្រាហ្មណ៍ក្នុងទីនេះឯង ជាការមិនសមគួរ ទើបនាំព្រាហ្មណ៍ទៅក្នុងបុរី ហើយប្រថាប់លើរាជាសនៈ ត្រាស់បង្គាប់ឲ្យហៅពេទ្យឈ្មោះសីវកៈមក ហើយត្រាស់ថា អ្នកចូរជម្រះភ្នែករបស់យើងឲ្យស្អាត ។ សំឡេងគឹកកងបានមានក្នុងនគរទាំងមូលថា បានឮថា ព្រះរាជារបស់យើង មានព្រះរាជ-បំណងនឹងឆ្កៀលព្រះនេត្រទាំងពីរ ព្រះរាជទានដល់ព្រាហ្មណ៍ ។ លំដាប់នោះ រាជវល្លភៈទាំងឡាយ (អ្នកស្និទ្ធស្នាលនឹងព្រះរាជា) មានសេនាបតីជាដើមផង អ្នកនគរទាំងឡាយផង ស្រីស្នំទាំងឡាយផង មកប្រជុំគ្នា កាលនឹងក្រាបទូលឃាត់ទានរបស់ព្រះរាជា បានពោលគាថាទាំងឡាយ ៣ ថា

មា ទេវ អទា ចក្ខុំ, មា នោ សព្ពេ បរាករិ;
ធនំ ទេហិ មហារាជ, មុត្តា វេឡុរិយា ពហូ។

*បពិត្រព្រះសម្មតិទេព សូមទ្រង់កុំប្រទាននូវព្រះនេត្រ សូមទ្រង់កុំលះបង់នូវពួកយើងទាំងអស់គ្នាឡើយ បពិត្រមហារាជ សូមទ្រង់ប្រទាននូវព្រះរាជទ្រព្យ គឺកែវមុក្តា និងកែវវិទូរ្យដ៏ច្រើន វិញចុះ ។*

យុត្តេ ទេវ រថេ ទេហិ, អាជានីយេ ចលង្កតេ;
នាគេ ទេហិ មហារាជ, ហេមកប្បនវាសសេ។

*បពិត្រសម្មតិទេព សូមទ្រង់ប្រទាននូវរថ ដែលទឹមដោយសេះអាជានីយ ដែលប្រថាប់ហើយ បពិត្រមហារាជ សូមព្រះអង្គប្រទាននូវដំរីទាំងឡាយ ប្រកបដោយគ្រឿងប្រដាប់ក្បាល គឺបណ្ដាញមាសវិញចុះ ។*

យថា តំ សិវយោ សព្ពេ, សយោគ្គា សរថា សទា;
សមន្តា បរិកិរេយ្យុំ, ឯវំ ទេហិ រថេសភា។

*រទាំងពួងព្រមទាំងខ្សែ ព្រមទាំងរាជរថចោមរោមព្រះអង្គដោយជុំវិញ គ្រប់កាល ដោយប្រការៈណា បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ សូមព្រះអង្គប្រទានដោយប្រការៈនោះចុះ ។*

*បណ្ដាបទទាំងនោះ បទថា* **បរាករិ** *ប្រែថា លះបង់ហើយ អធិប្បាយថា អ្នកដែនសិវិទាំងឡាយនាំគ្នាក្រាបទូលដោយសេចក្ដីប្រាថ្នាដូចគ្នាថា កាលព្រះអង្គព្រះរាជទានព្រះនេត្រហើយ ព្រះអង្គនឹងគ្រប់គ្រងរាជសម្បត្តិមិនបាន មនុស្សដទៃនឹងគ្រប់គ្រងជំនួស កាលជាយ៉ាងនេះ ខ្ញុំព្រះករុណាទាំងឡាយ នឹងឈ្មោះថា ជាអ្នកដែលព្រះអង្គលះបង់ហើយ ។ បទថា ប្រែថា* **បរិកិរេយ្យុំ** *គប្បីឡោមព័ទ្ធ ។ បទថា* **ឯវំ ទេហិ** *សេចក្ដីថា អ្នកដែនសិវិទាំងឡាយនឹងគប្បីចោមរោមព្រះអង្គអ្នកព្រះនេត្រមិនវិកល ដោយវិធីយ៉ាងណា សូមព្រះអង្គព្រះរាជទានដោយវិធីយ៉ាងនោះចុះ គឺព្រះអង្គចូរព្រះរាជទានត្រឹមតែទ្រព្យដល់*

ព្រាហ្មណ៍ប៉ុណ្ណោះ កុំព្រះរាជទានព្រះនេត្រទាំងពីរឡើយ ព្រោះកាលព្រះអង្គព្រះរាជទានព្រះនេត្រទាំងពីរហើយ ប្រជារាស្ត្រអ្នកដែនសិវិទាំងឡាយ នឹងមិនចោមរោមព្រះអង្គតទៅ ។

លំដាប់នោះ ព្រះរាជាបានត្រាស់ព្រះគាថាទាំងឡាយ ៣ ថា

យោ វេ ទស្សន្តិ វត្វាន, អទានេ កុរុតេ មនោ;
ភូម្យំ សោ បតិតំ ចាសំ, គីវាយំ បដិមុញ្ចតិ។

បុគ្គលណាពោលថាអាត្មាអញនឹងឲ្យ ហើយធ្វើនូវចិត្ត ក្នុងការមិនឲ្យវិញ បុគ្គលនោះ ឈ្មោះថាយកអន្ទាក់ដែលធ្លាក់លើផែនដីមកពាក់ឰដក ។

យោ វេ ទស្សន្តិ វត្វានំ, អទានេ កុរុតេ មនោ;
បាបា បាបតរោ ហោតិ, សម្បត្តោ យមសាធនំ។

បុគ្គលណាពោលថាអាត្មាអញនឹងឲ្យ ហើយធ្វើនូវចិត្តក្នុងការមិនឲ្យវិញ បុគ្គលនោះ ឈ្មោះថាជាបុគ្គលលាមកក្រៃលែងជាងបុគ្គលលាមក ហើយដល់នូវឋាននរកជាទីសម្រេចរបស់យមរាជ ។

យញ្ហិ យាចេ តញ្ហិ ទទេ, យំ ន យាចេ ន តំ ទទេ;
ស្វាហំ តមេវ ទស្សាមិ, យំ មំ យាចតិ ព្រាហ្មណោ។

ស្មូមសូមនូវរបស់ណា បុគ្គលគួរតែឲ្យនូវរបស់នោះ មិនសូមនូវរបស់ណា មិនត្រូវឲ្យរបស់នោះទេ ព្រាហ្មណ៍សូមនូវរបស់ណានឹងអាត្មាអញ អាត្មាអញនោះនឹងឲ្យនូវរបស់នោះឯង ។

បណ្ដាបទទាំងនោះ បទថា **បដិមុញ្ចតិ** សេចក្ដីថា ឲ្យចូលទៅ ។ បទថា សេចក្ដីថា **តាតា តាបតរោ** រមែងឈ្មោះថា ជាបុគ្គលអាក្រក់លាមកជាងបុគ្គលអាក្រក់លាមក ។ បទថា **សម្បត្តោ យមសាធនំ** សេចក្ដីថា រមែងជាអ្នកឈ្មោះថាដល់ឧស្សុទនរក ដែលជាស្ថានទីមានអាជ្ញានៃស្ដេចយមរាជដោយពិត ។ បទថា **យញ្ហិ យាចេ** សេចក្ដីថា ព្រះបាទសិវិត្រាស់ថា បើយាចកគប្បីសូមរបស់ណា សូម្បីទាយកក៏ត្រូវឲ្យរបស់នោះ ក៏ព្រាហ្មណ៍នេះសូមចក្ខុនឹងយើង មិនមែនសូមទ្រព្យមានកែវមុក្តាជាដើម យើងនឹងឲ្យចក្ខុដល់ព្រាហ្មណ៍ប៉ុណ្ណោះ ។

លំដាប់នោះ កាលអាមាត្យទាំងឡាយ កាលទូលសួរព្រះរាជាថា ព្រះអង្គនឹងព្រះរាជទានព្រះនេត្រ ព្រោះប្រាថ្នាអ្វី ? ទើបពោលគាថាថា

អាយុំ នុ វណ្ណំ នុ សុខំ ពលំ នុ,
កិំ បត្ថយានោ នុ ជនិន្ទ ទេសិ;

កាមញ្ហិ រាជា សិវីនំ អនុត្តរោ,
ចក្ខូនិ ទត្វា បរលោកហេតុ។

*បពិត្រព្រះអង្គជាធំជាងជន ព្រះអង្គប្រាថ្នានូវរបស់អ្វី គឺអាយុ ឬពណ៌សម្បុរ ឬសេចក្តីសុខ ឬក៏កម្លាំង ទើបព្រះអង្គប្រទាន (ព្រះនេត្រ) ព្រះរាជាទ្រង់ប្រសើរជាងជន អ្នកនៅក្នុងដែនសិវិទាំងឡាយ មិនសមបើប្រទានព្រះនេត្រទាំងឡាយ ព្រោះហេតុនៃប្រយោជន៍ក្នុងបរលោក ។*

*បណ្តាបទទាំងនោះ បទថា* **បរលោកហេតុ** *សេចក្តីថា បពិត្រមហារាជ ឈ្មោះថាបុរសជាបណ្ឌិតដូចព្រះអង្គ ចាំបាច់លះឥស្សរិយយសជាចំណែកបច្ចុប្បន្នហើយ ព្រះរាជទានព្រះនេត្រ ព្រោះហេតុនៃបរលោកឬ ?*

*លំដាប់នោះ ព្រះរាជាកាលនឹងត្រាស់តបអាមាត្យទាំងនោះ ទើបត្រាស់ព្រះគាថា ថា*

ន វាហមេតំ យសសា ទទាមិ,
ន បុត្តមិច្ឆេ ន ធនំ ន រដ្ឋំ;
សតញ្ច ធម្មោ ចរិតោ បុរាណោ,
ឥច្ចេវ ទានេ រមតេ មនោ មម។

អញមិនមែនឲ្យចក្ខុនេះ ព្រោះយសទេ មិនមែនប្រាថ្នាកូន មិនមែនប្រាថ្នាទ្រព្យ មិនមែនប្រាថ្នានូវដែនទេ ធម៌គឺប្រវេណីនៃការឲ្យទានជាផ្លូវបុរាណ ដែលពួកសប្បុរសធ្លាប់ប្រព្រឹត្តមកហើយ ចិត្តរបស់អញតែងរីករាយក្នុងការឲ្យ ដោយប្រការដូច្នេះឯង ។

បណ្ដាបទទាំងនោះ បទថា **ន ចាហំ** កាត់បទជា **ន ច អហំ** ។ បទថា **យសសា** សេចក្ដីថា ព្រោះហេតុនៃយសដែលជាទិព្វ ឬជារបស់មនុស្ស ក៏រកមិនបាន ។ បទថា **ន បុត្តមិច្ឆេ** សេចក្ដីថា យើងមិនមែនប្រាថ្នាបុត្រ មិនប្រាថ្នាទ្រព្យ មិនប្រាថ្នាដែន ព្រោះផលនៃចក្ខុទាននេះឡើយ តែថាអំពើនេះ ឈ្មោះថាបោរាណកមគ្គ ដែលសប្បុរសគឺបណ្ឌិតទាំងឡាយ ដែលជាព្រះសព្វញ្ញុពោធិសត្វ សន្សំមកហើយ គឺសន្សំដល់ព្រមហើយ ។ ពិតមែន ព្រះពោធិសត្វមិនបំពេញនូវបារមីទាំងឡាយហើយ ឈ្មោះថា អាចដើម្បីបន្ទុះសព្វញ្ញុតញ្ញាណលើពោធិបល្ល័ង្ក មិនមានឡើយ, ក៏ឯយើងបំពេញបារមីទាំងឡាយប្រាថ្នាឲ្យបានជាព្រះពុទ្ធ ។ បទថា **តស្មា ទានេ រមតេ មនោ មម** សេចក្ដីថា ព្រះរាជាត្រាស់ថា ព្រោះហេតុនេះ ចិត្តរបស់យើងទើបត្រេកអរស៊ប់ហើយ ក្នុងទានប៉ុណ្ណោះ ។

*សូម្បីព្រះសម្មាសម្ពុទ្ធ កាលទ្រង់សម្តែងចរិយាបិដក ដល់ព្រះធម្មសេនា-បតីសារីបុត្រ ដើម្បីសម្តែងថា សព្វញ្ញុតញ្ញាណប៉ុណ្ណោះជាទីស្រឡាញ់ជាងព្រះនេត្រទាំងពីររបស់យើង ទើបត្រាស់ថា*

ន មេ ទេស្សា ឧភោ ចក្ខូ, អត្តានំ មេ ន ទេស្សិយំ;
សព្ពញ្ញុតំ បិយំ មយ្ហំ, តស្មា ចក្ខុំ អទាសហំ។

***ភ្នែកទាំងពីរ មិនជាទីស្អប់ របស់តថាគតទេ តថាគតមិនមែនស្អប់ខ្លួនរបស់តថាគតទេ សព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតឲ្យនូវភ្នែក ។***

*កាលអាមាត្យទាំងឡាយ បានស្តាប់ព្រះតម្រាស់របស់ព្រះមហាសត្វហើយ មិនអាចនឹងទូលឃាត់ ត្រូវអង្គុយស្ងៀម ព្រះមហាសត្វបានត្រាស់នឹងសីវិកពេទ្យដោយគាថាថា*

សខា ច មិត្តោ ច មមាសិ សីវិក,
សុសិក្ខិតោ សាធុ ករោហិ មេ វចោ;
ឧទ្ធរិត្វា ចក្ខូនិ មមំ ជិគីសតោ,
ហត្ថេសុ ឋបេហិ វនិព្ពកស្ស។

ម្នាលពេទ្យឈ្មោះសីវិកៈ ខ្លួនអ្នកជាសំឡាញ់ ជាមិត្តរបស់យើង អ្នកមានវិជ្ជាពេទ្យសិក្សាល្អហើយ ចូរធ្វើតាមសំដីរបស់យើង ដោយប្រពៃចុះ កាលយើងកំពុងប្រាថ្នា អ្នកចូរឆ្កៀលនូវភ្នែកទាំងឡាយ (របស់យើង) ហើយដាក់លើដៃរបស់ស្មូមចុះ ។

ព្រះគាថានេះមានអត្ថាធិប្បាយថា ម្នាលសីវិកពេទ្យ អ្នកជាសំឡាញ់ និងជាមិត្ររបស់យើង អ្នកមានវិជ្ជាពេទ្យដែលសិក្សាមកល្អហើយ ចូរធ្វើតាមរបស់យើងឲ្យសម្រេចប្រយោជន៍ កាលយើងពិចារណាគឺជាសម្លឹងមើលនោះឯង អ្នកចូរឆ្កៀលនូវភ្នែកទាំងឡាយរបស់យើង ដូចជាសាច់ត្នោត ហើយដាក់ទុកក្នុងដៃទាំងឡាយរបស់យាចកនេះចុះ ។

លំដាប់នោះ សីវិកពេទ្យទូលនឹងព្រះរាជាថា ដែលឈ្មោះថាការឲ្យភ្នែកជាទាន ជាកម្មធ្ងន់ សូមព្រះសម្មតិទេព ចូរពិចារណាឲ្យល្អ ។ ព្រះរាជាត្រាស់ថា ម្នាលសីវិកពេទ្យ យើងពិចារណាល្អហើយ លោកកុំធ្វើឲ្យយឺតយូរឡើយ កុំនិយាយច្រើននឹងយើងឡើយ ។ សីវិកពេទ្យគិតថា ការដែលពេទ្យអ្នកមានការសិក្សាល្អដូចយើង នឹងយកសស្ត្រាដាក់ចុះព្រះនេត្ររបស់ព្រះរាជា មិនសមគួរឡើយ ។ ពេទ្យនោះទើបត្រដុសឱសថផ្សេងៗ យកផ្កាឧប្បលខៀវលាយលម្អិតឱសថ ហើយថ្វាយឲ្យទ្រង់ជូតព្រះនេត្រខាងស្តាំ ព្រះនេត្រក៏ប្រែប្រួល ទុក្ខ-វេទនា ក៏កើតឡើង ។ ពេទ្យក្រាបទូលថា បពិត្រមហារាជ សូមព្រះអង្គចូរ

កំណត់ព្រះទ័យចុះ ការធ្វើព្រះនេត្រឲ្យជាប្រក្រតី ជាភារៈរបស់ខ្ញុំព្រះករុណា ។ ព្រះរាជាត្រាស់ថា ម្នាលពេទ្យ អ្នកចូរកុំធ្វើដំណើរយឺតយូរឡើយ ។ ពេទ្យទើបផ្សំឱសថបង្អោនចូលទៅថ្វាយ ឲ្យទ្រង់ជូតព្រះនេត្រខាងឆ្វេងទៀត ព្រះនេត្រក៏របេះចាករណ្តៅភ្នែក ទុក្ខវេទនាដ៏ខ្លាំងរមែងកើតឡើង ។ ពេទ្យក្រាបទូលថា បពិត្រមហារាជ សូមព្រះអង្គកំណត់ព្រះទ័យចុះ ការធ្វើព្រះនេត្រឲ្យជាប្រក្រតី ជាភារៈរបស់ខ្ញុំព្រះករុណា ។ ម្នាលពេទ្យ អ្នកចូរកុំធ្វើដំណើរយឺតយូរឡើយ ។ ក្នុងវារៈទី ៣ ពេទ្យនោះផ្សំឱសថឲ្យខ្លាំងជាងមុន ហើយបង្អោនថ្វាយ ។ ព្រះនេត្រវិលទៅហើយដោយកម្លាំងនៃឱសថ របូតចាកហើយពីរណ្តៅព្រះនេត្រព្យួរសំយុងចុះដោយសរសៃ ។ ពេទ្យនោះទើបក្រាបទូលទៀតថា បពិត្រព្រះអង្គជាធំជាជន សូមព្រះអង្គកំណត់ព្រះទ័យពិចារណាចុះ ការធ្វើព្រះនេត្រឲ្យជាប្រក្រតីជាភារៈរបស់ខ្ញុំព្រះករុណា ។ ព្រះរាជាត្រាស់ថា អ្នកចូរកុំធ្វើដំណើរឲ្យយឺតយូរឡើយ ។ ទុក្ខវេទនាមានប្រមាណដ៏ក្រៃលែង ក៏កើតឡើង, លោហិតហូរចេញ, ព្រះកូសាទទឹកហើយដោយលោហិត ។ នាងស្នំនិងពួកអាមាត្យទាំងឡាយ ក្រាបចុះទៀបព្រះបាទនៃព្រះរាជា នាំគ្នាទួញសោក បរិវេទនាការដ៏ធំថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំឲ្យនូវព្រះនេត្រទាំងឡាយឡើយ ។ ព្រះរាជាទ្រង់អត់សង្កត់នូវទុក្ខវេទនា ត្រាស់ថា ម្នាលពេទ្យ អ្នកកុំធ្វើឲ្យយឺតយូរឡើយ ។ ពេទ្យនោះពោលថា សាធុ ទេវៈ ប្រពៃហើយ ព្រះអង្គ ហើយទ្រនូវព្រះ

នេត្រដោយដៃឆ្វេង ចាប់សស្ត្រាកាត់សរសៃដែលតភ្ជាប់នឹងភ្នែកដោយដៃស្ដាំ កាន់យកព្រះនេត្រដាក់ទុកលើព្រះហស្តរបស់ព្រះមហាសត្វ ។ ព្រះរាជាទតព្រះនេត្រខាងស្ដាំដោយព្រះនេត្រខាងឆ្វេង ទ្រង់អត់សង្កត់នូវទុក្ខវេទនា ត្រាស់ហៅព្រាហ្មណ៍ថា ម្នាលព្រាហ្មណ៍ អ្នកចូរមក ហើយត្រាស់ថា ភ្នែកគឺសព្វញ្ញុតញ្ញាណប៉ុណ្ណោះ ជាទីស្រឡាញ់ជាងភ្នែករបស់យើង ដោយរយនៃគុណ ដោយពាន់នៃគុណ ដោយសែននៃគុណ សូមចក្ខុទានរបស់យើងនេះ ចូរជាបច្ច័យ នៃសព្វញ្ញុតញ្ញាណនោះចុះ ហើយបានព្រះរាជទានព្រះនេត្រដល់ព្រាហ្មណ៍ ។ ព្រាហ្មណ៍នោះលើកឡើងនូវព្រះនេត្រនោះ ដាក់ទុកក្នុងភ្នែករបស់ខ្លួន ។ ដោយអានុភាពនៃព្រះបាទសិវិនោះ ភ្នែកនោះក៏បានប្រតិស្ឋានទុក ហាក់ដូចជាផ្កាឧប្បលខៀវដែលរីកហើយ ។ ព្រះមហាសត្វបានឃើញភ្នែកនោះរបស់ព្រាហ្មណ៍នោះ ដោយព្រះនេត្រខាងឆ្វេង ហើយទ្រង់ព្រះតម្រិះថា ឱ! អក្ខិទានគឺយើងបានឲ្យហើយដោយល្អ ទ្រង់សោយបីត ដែលជ្រួតជ្រាបទៅខាងក្នុងព្រះហឫទ័យជានិច្ច ទើបបានព្រះរាជទានព្រះនេត្រឆ្វេងទៀត ។ សក្កទេវរាជក៏ប្រតិស្ឋានសូម្បីព្រះនេត្រឆ្វេងនោះក្នុងភ្នែករបស់ព្រះអង្គ ហើយស្ដេចចេញចាកព្រះរាជនិវេសន៍ កាលមហាជនកំពុងក្រឡេកមើលនោះឯង បានចេញចាកព្រះនគរ ទៅកាន់ទេវលោក ។

ព្រះសាស្ដាកាលប្រកាសសេចក្ដីនោះ ទើបត្រាស់ ១ គាថាកន្លះថា

ចោទិតោ សិវិរាជេន,    សិវិកោ វចនំករោ;
រញ្ញោ ចក្ខូនុទ្ធរិត្វា,    ព្រាហ្មណស្សូបនាមយិ;
សចក្ខុ ព្រាហ្មណោ អាសិ,    អន្ធោ រាជា ឧបាវិសិ។

*ពេទ្យឈ្មោះសីវិកៈ លុះព្រះរាជាទ្រង់ព្រះនាមសិវិ តឿន (យ៉ាងនេះហើយ) ក៏ធ្វើតាមព្រះបន្ទូល ហើយឆ្កៀលនូវព្រះនេត្រទាំងពីររបស់ព្រះរាជា បង្អោនទៅឲ្យព្រាហ្មណ៍ ចំណែកព្រាហ្មណ៍ក៏ទៅជាបុគ្គលមានភ្នែក ព្រះរាជាទៅជាបុគ្គលខ្វាក់ ។*

*មិនយូរប៉ុន្មានឡើយ ព្រះនេត្ររបស់ព្រះរាជាក៏ដុះឡើង កាលដុះឡើងមិនបានដល់ភាពជារណ្ដៅ ពេញដោយដុំសាច់ដែលទៅខាងលើ ហាក់បីដូជាផ្ទុកសំពត់កម្ពល ភ្នែកទាំងឡាយបានមានហើយ ហាក់ដូចជារូបវិចិត្តកម្ម ទុក្ខ-វេទនា ក៏ដាច់សូន្យទៅ ។ គ្រានោះ ព្រះមហាសត្វប្រថាប់នៅលើប្រាសាទពីរបីថ្ងៃ ទ្រង់ត្រិះរិះថា ប្រយោជន៍អ្វីដោយរាជសម្បត្តិរបស់មនុស្សខ្វាក់ ព្រោះហេតុនោះ យើងនឹងប្រគល់រាជសម្បត្តិ ដល់អាមាត្យទាំងឡាយ ហើយទៅកាន់ឧទ្យាន បួសហើយ យើងនឹងសមណធម៌ចុះ ដូចនេះហើយ ត្រាស់បង្គាប់ឲ្យអាមាត្យទាំងឡាយចូលគាល់ ត្រាស់ប្រាប់សេចក្ដីនោះ ដល់អាមាត្យទាំងនោះ ហើយបញ្ជាថា កប្បិយការកៈម្នាក់ប៉ុណ្ណោះ សម្រាប់ឲ្យរបស់របរ មានទឹកលុបមុខជាដើម នឹងនៅក្នុងសំណាក់យើង អ្នកទាំងឡាយចូរចងនូវខ្សែទុកក្នុងទីធ្វើ*

សរីរកិច្ចដល់យើង ហើយត្រាស់ហៅនាយសារថីមកបញ្ជាថា អ្នកចូរទឹមរថ ។ ចំណែកអាមាត្យទាំងឡាយ មិនឲ្យព្រះអង្គទៅដោយរថ នាំព្រះអង្គទៅដោយសុវណ្ណសីវិកា (គ្រែស្នែងមាស) ហើយឲ្យប្រថាប់នៅជិតច្រាំងនៃស្រះបោក្ខរណី ចាត់ចែងកម្លាំងថែរក្សា ហើយទើបត្រឡប់ទៅ ។ ព្រះរាជាប្រថាប់លើបល្ល័ង្ក ទ្រង់ពិចារណាដល់ទានរបស់ព្រះអង្គ ។ ក្នុងខណៈនោះ អាសនៈរបស់ស្ដេចសក្កៈមានអាការៈក្ដៅ ។ ស្ដេចសក្កៈនោះ ពិចារណាមើលបានឃើញនូវហេតុនោះ ទ្រង់ត្រិះរិះថា យើងនឹងឲ្យពរដល់សិវិមហារាជ ហើយនឹងធ្វើព្រះនេត្រឲ្យប្រក្រតី ដូចនេះហើយ ស្ដេចមកត្រង់ច្រាំងនៃស្រះបោក្ខរណីនោះ ស្ដេចយាងទៅយាងមក ក្នុងទីមិនឆ្ងាយពីព្រះមហាសត្វ ។

ព្រះសាស្ដាកាលទ្រង់ប្រកាសសេចក្ដីនោះ ទើបត្រាស់ថា

តតោ សោ កតិចាហស្ស, ឧបរូឡ្ហេសុ ចក្ខុសុ;
សូតំ អាមន្តយី រាជា, សិវីនំ រដ្ឋវឌ្ឍនោ។

តអំពីនោះមក ប្រមាណពីរបីថ្ងៃ លុះដល់ព្រះនេត្រទាំងពីរដុះឡើង ព្រះរាជា ជាអ្នកញុំាងដែនឲ្យចម្រើនដល់ពួកជនអ្នកសិវិ ។

យោជេហិ សារថិ យានំ, យុត្តញ្ច បដិវេទយ;
ឧយ្យានភូមឹ គច្ឆាម, ពោក្ខរញ្ញោ វនានិ ច។

ទ្រង់ត្រាស់បង្គាប់នាយសារថីថា នែនាយសារថី អ្នកចូរទឹមយាន លុះទឹមហើយចូរប្រាប់យើង យើងនឹងទៅកាន់ទីឧទ្យាន ដែលមានស្រះបោក្ខរណីនិងព្រៃព្រឹក្សា ។

សោ ច ពោក្ខរណីតីរេ, បល្លង្កេន ឧបាវិសិ;
តស្ស សក្កោ បាតុរហុ, ទេវរាជា សុជម្បតិ។

ព្រះបាទសិវិនោះ ទ្រង់បានចូលទៅគង់លើពែនភ្នែន ប្របមាត់ស្រះបោក្ខរណីទេវរាជឈ្មោះសក្កៈ ជាសុជម្បតិ ក៏មកដល់ចំពោះព្រះអង្គ ។

ចំណែកសក្កទេវរាជ ដែលព្រះមហាសត្វទ្រង់ស្តាប់សំឡេងនៃព្រះបាទហើយត្រាស់សួរថា អ្នកណាហ្នឹង ? ទើបត្រាស់ព្រះគាថាថា

សក្កោហមស្មិ ទេវិន្ទោ, អាគតោស្មិ តវន្តិកេ;
វរំ វរស្សុ រាជីសិ, យំ កិញ្ចិ មនសិច្ឆសិ។

ខ្ញុំជាទេវរាជឈ្មោះសក្កៈ ជាធំជាងទេវតា មកក្នុងសំណាក់ព្រះអង្គ បពិត្រស្តេចឥសី ព្រះអង្គប្រាថ្នាក្នុងព្រះទ័យចំពោះពរណាមួយ សូមត្រេកអរនឹងពរនោះចុះ ។

កាលសក្កទេវរាជត្រាស់យ៉ាងនេះហើយ ព្រះរាជាបានត្រាស់ព្រះគាថាថា

បហូតំ មេ ជនំ សក្ក, ពលំ កោសោ ចនប្បកោ;
អន្ធស្ស មេ សតោ ទានិ, មរណញ្ញេវ រុច្ចតិ។

*បពិត្រសក្កៈ ទ្រព្យនិងពលរបស់ខ្ញុំមានច្រើនហើយ ទាំងឃ្លាំងរបស់ខ្ញុំ មិនមែនមានតិចទេ កាលបើខ្ញុំនៅតែខ្វាក់ ក្នុងកាលឥឡូវនេះ ខ្ញុំពេញចិត្តចំពោះសេចក្ដីស្លាប់តែម្យ៉ាង ។*

*បណ្ដាបទទាំងនោះ បទថា* **មរណញ្ញេវ រុច្ចតិ** *សេចក្ដីថា បពិត្រទេវរាជឥឡូវនេះ សេចក្ដីស្លាប់តែម្យ៉ាងប៉ុណ្ណោះ ដែលខ្ញុំពេញចិត្តព្រោះភាពជាមនុស្សខ្វាក់ភ្នែក សូមព្រះអង្គចូរឲ្យសេចក្ដីស្លាប់ដល់ខ្ញុំចុះ ។*

*លំដាប់នោះ សក្កទេវរាជបានត្រាស់នឹងព្រះរាជាថា បពិត្រព្រះបាទសិវិ ព្រះអង្គប្រាថ្នាសេចក្ដីស្លាប់ ទើបពេញចិត្តសេចក្ដីស្លាប់ ឬប្រាថ្នាសេចក្ដីស្លាប់ព្រោះភាពជាមនុស្សខ្វាក់ ? ព្រះបាទសិវិរាជទូលតបថា បពិត្រទេវៈ ខ្ញុំប្រាថ្នាសេចក្ដីស្លាប់ព្រោះភាពជាមនុស្សខ្វាក់ ។ សក្កទេវរាជត្រាស់តបថា បពិត្រមហារាជ ឈ្មោះថាទាន មិនមែនឲ្យផលតែក្នុងសម្បរាយភពប៉ុណ្ណោះទាំងអស់ទេ រមែងជាបច្ច័យសូម្បីក្នុងប្រយោជន៍បច្ចុប្បន្ន ព្រះអង្គដែលយាចកទូលសូមព្រះនេត្រម្ខាង បានព្រះរាជទានទាំងពីរខាង ហេតុនោះ ព្រះអង្គមេត្តាធ្វើសច្ចកិរិយាចុះ ហើយត្រាស់ថា*

យានិ សច្ចានិ ទ្វិបទិន្ទ, តានិ ភាសស្សុ ខត្តិយ;
សច្ចំ តេ ភណមានស្ស, បុន ចក្ខុ ភវិស្សតិ។

*បពិត្រក្សត្រិយ៍ជាធំជាងជនមានជើងពីរ សូមព្រះអង្គពោលនូវពាក្យទាំងឡាយដែលជាសច្ចៈចុះ កាលបើព្រះអង្គពោលនូវពាក្យសច្ចៈ ព្រះនេត្រនឹងមានឡើងវិញ ។*

*ព្រះមហាសត្វស្តាប់ពាក្យនោះហើយត្រាស់ថា បពិត្រសក្កទេវរាជ ប្រសិនបើព្រះអង្គប្រាថ្នាប្រទានចក្ខុដល់ខ្ញុំ សូមកុំធ្វើឧបាយដទៃឡើយ ចក្ខុចូរកើតឡើងដល់ខ្ញុំ ដោយផលនៃទានរបស់ខ្ញុំប៉ុណ្ណោះ កាលសក្កទេវរាជត្រាស់ថា បពិត្រមហារាជ យើងជាសក្កៈ សូម្បីជាស្តេចនៃទេវតា ក៏មិនអាចដើម្បីនឹងឲ្យនូវចក្ខុដល់អ្នកដទៃឡើយ ចក្ខុនឹងកើតឡើងដល់ព្រះអង្គដោយផលនៃទានដែលព្រះអង្គបានឲ្យហើយប៉ុណ្ណោះ ព្រះបាទសិវិត្រាស់ថា ពិតមែនហើយ ទានគឺយើងបានហើយឲ្យដោយល្អ កាលធ្វើសច្ចកិរិយា ទើបពោលគាថាថា*

យេ មំ យាចិតុមាយន្តិ, នានាគោត្តា វនិព្វកា;
យោបិ មំ យាចតេ តត្ថ, សោបិ មេ មនសោ បិយោ;
ឯតេន សច្ចវជ្ជេន, ចក្ខុ មេ ឧបបជ្ជថ។

ពួកស្មូមណាមានគោត្រផ្សេងៗគ្នា មកដើម្បីសូមចំពោះយើង បណ្តាស្មូមទាំងនោះ ស្មូមណាសូមយើង ស្មូមនោះជាទីស្រឡាញ់ នៃចិត្តរបស់យើង សូមឲ្យភ្នែកកើតមានដល់យើង ដោយការពោលនូវពាក្យសច្ចៈនេះ ។

បណ្តាបទទាំងនោះ បទថា **យេ មំ** សេចក្តីថា ស្មូមទាំងឡាយណាមកសូមនឹងយើង កាលស្មូមទាំងនោះមកសូមនឹងយើង សូម្បីស្មូមនោះរមែងជាទីស្រឡាញ់ពេញចិត្តរបស់យើង ។ បទថា **ឯតេន** សេចក្តីថា ប្រសិនបើ យាចកសូម្បីទាំងអស់ជាទីស្រឡាញ់របស់យើង នេះជាសច្ចវាចាដែលយើងបានពោលហើយ ដោយការពោលសច្ចវាចានេះ សូមចក្ខុម្ខាងរបស់យើងចូរកើតឡើងចុះ។

លំដាប់នោះ ចក្ខុទី ១ ក៏កើតឡើងក្នុងរវាងនៃព្រះតម្រាស់របស់ព្រះរាជានោះឯង ។ តអំពីនោះ ព្រះរាជាក៏ត្រាស់ព្រះគាថាទាំងឡាយ ២ ដើម្បីប្រយោជន៍ដល់ការកើតនៃចក្ខុទី ២ ថា

យំ មំ សោ យាចិតុំ អាគា, ទេហិ ចក្ខុន្តិ ព្រាហ្មណោ;
តស្ស ចក្ខូនិ ទានាសិំ, ព្រាហ្មណស្ស វនិព្វតោ។

ព្រាហ្មណ៍នោះមក ដើម្បីសូមនូវភ្នែកណានឹងយើងថា សូមព្រះអង្គប្រទាននូវភ្នែក យើងក៏បានឲ្យនូវភ្នែកទាំងឡាយនោះ ដល់ព្រាហ្មណ៍ដែលសូមនោះហើយ ។

កិំ យោ្យា មំ អាវិសី បីតិ, សោមនស្សញ្ចានប្បកំ;
ឃតេន សច្ចវជ្ជេន, ទុតិយំ មេ ឧបបជ្ជថ។

*បីតិនិងសោមនស្សដ៏ច្រើនក៏កើតឡើងដល់យើង ដោយក្រៃលែង សូមឲ្យភ្នែកជាគម្រប់ពីរកើតមានដល់យើង ដោយពោលពាក្យសច្ចៈនេះ ។*

*បណ្ដាបទទាំងនោះ បទថា* **យំ មំ** *សេចក្ដីថា ព្រាហ្មណ៍មកសូមនឹងយើង ។ បទថា* **សោ** *សេចក្ដីថា ព្រាហ្មណ៍នោះអ្នកមានចក្ខុពិការមកដើម្បីសូមយើងថា សូមព្រះអង្គមេត្តាប្រទានចក្ខុដល់ខ្ញុំ ។ បទថា* **វណិព្វតោ** *សេចក្ដីថាដល់ព្រាហ្មណ៍អ្នកមកសូម ។ បទថា* **កិំ យោ្យា មំ អាវិសិ** *សេចក្ដីថា គ្រាឲ្យចក្ខុ ទាំងពីរដល់ព្រាហ្មណ៍ហើយ រាប់តាំងតែអំពីកាលនោះមកក៏ជាមនុស្សខ្វាក់ មិនអើពើនូវទុក្ខវេទនាដែលមានសភាពដូចនោះ ក្នុងកាលដ៏ឹតនោះឡើយ បីតីដ៏ខ្លាំងក្លាផ្សាយទៅ គឺចូលទៅកាន់ហឫទ័យរបស់យើង អ្នកពិចារណាថា ឱ !ទានគឺយើងបានឲ្យដោយល្អ ទាំងសេចក្ដីសោមនស្សដ៏អបរិមាណជាអនន្តក៏កើតដល់យើង ។ បទថា* **ឃតេន** *សេចក្ដីថា ប្រសិនបើបីតិសោមនស្សមិនមែនតិចកើតឡើងដល់យើង ក្នុងកាលនោះសោត នេះជាសច្ចវាចាដែលយើងបានពោលហើយ ដោយការពោលសច្ចវាចានេះ ចក្ខុសូម្បីទី ២ ចូរកើតឡើងដល់យើងចុះ ។*

ក្នុងខណៈនោះឯង ព្រះនេត្រដួងទី ២ ក៏កើតឡើង ។ តែព្រះនេត្ររបស់ព្រះបាទសិវិនោះ មិនមែនជាព្រះនេត្រធម្មតា ហើយក៏មិនមែនជាព្រះនេត្រទិព្វ ។ ព្រោះព្រះនេត្ររបស់ព្រះអង្គទ្រង់ប្រទា នដល់សក្កព្រាហ្មណ៍ហើយ ទាំងសក្ក-ព្រាហ្មណ៍ក៏មិនអាចធ្វើព្រះនេត្រ ឲ្យជាប្រក្រតីដូចដើមឡើយ ម្យ៉ាងទៀត ឈ្មោះថា ចក្ខុជាទិព្វរមែងមិនកើតដល់វត្ថុដែលវិនាសហើយឡើយ ព្រោះហេតុនោះ ព្រះនេត្រទាំងនោះ របស់ព្រះបាទសិវិនោះ ត្រូវហៅថា សច្ចបារមិតាចក្ខុ គឺចក្ខុដែលកើតឡើងដោយអានុភាពនៃសច្ចបារមី ។ ក្នុងកាលព្រះនេត្រទាំងនោះកើតឡើង ព្រមគ្នានោះឯង រាជបរិវារទាំងពួងបានមកប្រជុំគ្នាហើយ ដោយអានុភាពរបស់ សក្កទេវរាជ ។ លំដាប់នោះ កាលសក្កទេវរាជធ្វើនូវការសរសើរព្រះបាទសិវិក្នុង កណ្តាលមហាជននោះឯង ទើបត្រាស់ព្រះគាថាទាំងឡាយ ២ ថា

ធម្មេន ភាសិតា គាថា, សិវីនំ រដ្ឋវឌ្ឍន;
ឯតានិ តវ នេត្តានិ, ទិព្ពានិ បដិទិស្សរេ។

បពិត្រក្សត្រិយ៍ អ្នកញុំាងដែនរបស់អ្នកដែនសីវិឲ្យចម្រើន គាថាដែលព្រះអង្គពោលតាមធម៌ សូមឲ្យព្រះនេត្រទាំងពីរ របស់ព្រះអង្គនេះប្រាកដដូចជា ទិព្វ ។

តិរោកុដ្ដំ តិរោសេលំ, សមតិគ្គយ្ហ បព្ពតំ;
សមន្តា យោជនសតំ, ទស្សនំ អនុភោន្តុ តេ។

*ព្រះនេត្រទាំងពីររបស់ព្រះអង្គនោះ សូមឲ្យបាននូវការឃើញធ្លុះធ្លាយ ទៅខាងក្រៅជញ្ជាំង ខាងក្រៅភ្នំថ្ម អស់ទីចំនួនមួយរយយោជន៍ ដោយជុំវិញ ។*

*បណ្ដាបទទាំងនោះ បទថា* **ធម្មេន ភាសិតា** *សេចក្ដីថា បពិត្រមហារាជ គាថាទាំងឡាយនេះ ព្រះអង្គពោលហើយតាមធម៌ គឺតាមសភាវៈ ។ បទថា* **ទិព្វានិ** *សេចក្ដីថា ប្រកបដោយអានុភាពដែលជាទិព្វ ។ បទថា* **បដិទិស្សរេ** *ប្រែថា នឹងប្រាកដ ។ បទថា* **តិរោកុដ្ដំ** *សេចក្ដីថា បពិត្រមហារាជ ព្រះនេត្រទាំងនោះរបស់ព្រះអង្គ មើលឃើញចាក់ធ្លុះ កន្លងផុតខាងក្រៅជញ្ជាំង គំនរនៃភ្នំ សូម្បីភ្នំយ៉ាងណាទីមួយ ហាក់បីដូចជាភ្នែកនៃទេវតាទាំងឡាយ រមែងសោយ គឺសម្រេចនូវការឃើញរូប អស់ទីចំនួន ១០០ យោជន៍ អំពីទិសទាំងឡាយ ១០ ដោយជុំវិញ ។*

*សក្កទេវរាជ ប្រថាប់ឈរលើអាកាស ត្រាស់ព្រះគាថាទាំងនេះ ក្នុងកណ្ដាលមហាជនហើយ ទ្រង់ប្រទានឱវាទព្រះមហាសត្វថា សូមព្រះអង្គកុំប្រមាទ ហើយស្ដេចទៅកាន់ទេវលោក ។*

ចំណែកមហាសត្វ ទ្រង់ឡោមព័ទ្ធដោយមហាជនស្ដេចចូលកាន់ព្រះនគរ ដោយសក្ការៈធំ ហើយស្ដេចឡើងកាន់សុចន្ទកប្រាសាទ ។ ភាពដែលព្រះបាទសិវិបានទ្រង់ចក្ខុទាំងគូដូចដើមវិញ បានប្រាកដក្នុងដែនសិវិទាំងមូល ។ លំដាប់នោះ អ្នកដែនសិវិទាំងអស់ កាន់គ្រឿងបណ្ណាការជាច្រើន មកហើយដើម្បីចូលគាល់ព្រះបាទសិវិ ។ ព្រះមហាសត្វទ្រង់ត្រិះរិះថា យើងពណ៌នានូវទានរបស់ក្នុងមហាសន្និបាតនេះ ទើបត្រាស់ឲ្យសាងមហាមណ្ឌប ត្រង់ទ្វារព្រះរាជ-និវេសន៍ ទ្រង់ប្រថាប់លើរាជបល្ល័ង្ក ខាងក្រោមសមុស្សិតស្វេតច្ឆត្រ ត្រាស់ឲ្យវាយស្គរប្រកាសក្នុងព្រះនគរ ឲ្យសេនាទាំងពួងប្រជុំគ្នាហើយត្រាស់ថា ម្នាលអ្នកដែនសិវិដ៏ចម្រើនទាំងឡាយ អ្នកទាំងឡាយបានឃើញព្រះនេត្រដែលដូចជាទិព្វរបស់យើងនេះ ចាប់អំពីនេះតទៅ បើមិនទាន់បានឲ្យទានជាមុន អ្នកទាំងឡាយកុំបរិភោគឡើយ កាលទ្រង់សម្ដែងធម្មទេសនា បានត្រាស់ព្រះគាថាទាំងឡាយ ៤ ថា

កោ នីធ វិត្តំ ន ទទេយ្យ យាចិតោ,
អបិ វិសិដ្ឋំ សុបិយម្បិ អត្តនោ;
តទិង្ឃ សព្ពេ សិវយោ សមាគតា,
ទិព្ពានិ នេត្តានិ មមជ្ជ បស្សថ។

អ្នកណាមួយក្នុងលោកនេះ ដែលគេសូម ហើយមិនឲ្យនូវទ្រព្យដ៏ពេញចិត្ត ឬទ្រព្យដ៏ថ្លៃថ្លា ជាទីស្រឡាញ់ ដ៏ក្រៃលែងរបស់ខ្លួន នៃអ្នកដែនសីវិទាំងអស់ដែលមកប្រជុំគ្នា ចូរអ្នកទាំងឡាយមើល នូវភ្នែកទាំងពីររបស់អញ ដែលដូចជាទិព្វក្នុងថ្ងៃនេះចុះ ។

តិរោកុឌ្ឌំ តិរោសេលំ, សមតិគ្គយ្ហ បព្ពតំ;
សមន្តា យោជនសតំ, ទស្សនំ អនុភោន្តិ មេ។

ចក្ខុទាំងពីររបស់យើង រមែងបាននូវការឃើញធ្លុះធ្លាយ ទៅខាងក្រៅជញ្ជាំង ខាងក្រៅភ្នំថ្ម អស់ទីចំនួនមួយរយយោជន៍ដោយជុំវិញ ។

ន ចាគមត្តា បរមត្ថិ កិញ្ចិ, មច្ចានំ ឥធ ជីវិតេ;
ទត្វាន មានុសំ ចក្ខុំ, លទ្ធំ មេ ចក្ខុំ អមានុសំ។

(វត្ថុណាមួយ) ក្នុងជីវិត របស់សត្វទាំងឡាយនេះ រមែងមិនប្រសើរជាងចាគៈទេ (ខ្លួនយើង) បានឲ្យនូវចក្ខុជារបស់មនុស្សហើយបាននូវចក្ខុទិព្វ ដែលមិនមែនជារបស់មនុស្ស ។

ឯតម្បិ ទិស្វា សិវយោ,
ទេថ ទានានិ កុព្វថ;

ឧត្វា ច កុត្វា ច យថានុការំ,
អនិន្ទិតា សគ្គមុបេថ ឋានំ។

*ម្នាលអ្នកដែនសិវិទាំងឡាយ អ្នកទាំងឡាយបានឃើញហេតុនេះហើយ ចូរឲ្យទាន ចូរបរិភោគ លុះឲ្យហើយបរិភោគហើយ តាមសមគួរដល់អនុភាព សូមឲ្យជាអ្នកមិនមានអ្នកណាតិះដៀលបាន ហើយចូរទៅកាន់ឋានសួគ៌ចុះ ។*

*បណ្ដាបទទាំងនោះ បទថា* **កោ ធីធ** *កាត់បទថា* **កោ នុ ឥធ** *ប្រែថា អ្នកណាក្នុងលោកនេះ ។ បទថា* **អបិ វិសិដ្ឋំ** *សេចក្ដីថា សូម្បីជារបស់វិសិដ្ឋ ។ បទថា* **ចាគមត្តា** *សេចក្ដីថា ឈ្មោះថារបស់ដទៃដែលនឹងប្រសើរជាងប្រមាណនៃទានរបស់យើងមិនមាន ។ បទថា* **ឥធ ជីវិតេ** *សេចក្ដីថា ក្នុងជីវលោកនេះ ។ បទថា* **អមានុសំ** *សេចក្ដីថា ចក្ខុដូចជាទិព្វដែលយើងបានហើយដោយហេតុនេះទើបគួរជ្រាបសេចក្ដីនេះថា ឈ្មោះថាវត្ថុដែលប្រសើរជាការបរិច្ចាគមិនមាន ។ បទថា* **ឯតម្បិ ទិស្វា** *សេចក្ដីថា អ្នកទាំងឡាយសូម្បីឃើញនូវចក្ខុដែលដូចជាទិព្វដែលយើងបានហើយ (ចូរឲ្យទានមុនទើបបរិភោគជាក្រោយ) ។*

*ព្រះបាទសិវិទ្រង់សម្ដែងធម៌ដោយគាថាទាំង ៤ នេះដោយប្រការដូច្នេះហើយ ចាប់ផ្ដើមអំពីនោះមក ក្នុងថ្ងៃបន្នរសុបោសថ (ឧបោសថថ្ងៃទី១៥) រាល់កន្លះខែទ្រង់ឲ្យមហាជនប្រជុំគ្នា ទ្រង់សម្ដែងធម៌ដោយគាថាទាំងនេះជាប្រចាំ ។*

មហាជនស្ដាប់ព្រះធម៌នោះហើយ នាំគ្នាធ្វើបុណ្យទាំងឡាយ មានឲ្យទានជាដើម កាលធ្វើឲ្យពេញនូវទេវលោក បានទៅកាន់ហើយទេវលោក ។

ព្រះសាស្ដាគ្រាទ្រង់នាំព្រះធម្មទេសនានេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បោរាណកបណ្ឌិតទាំងឡាយ មិនត្រេកអរដោយពាហិរទាន បានឆ្កៀលនូវភ្នែកទាំងពីររបស់ខ្លួនឲ្យជាទាន ដល់យាចកអ្នកមកដល់ចំពោះមុខដោយអាការៈយ៉ាងនេះ ហើយទ្រង់ប្រកាសចតុរារិយសច្ច ប្រជុំជាតកថា

តទា សីវិកាវេជ្ជោ អានន្ទោ អហោសិ សីវិកពេទ្យក្នុងកាលនោះបានមកជាអានន្ទ ។

សក្កោ អនុរុទ្ធោ អហោសិ សក្កទេវរាជបានមកជាអនុរុទ្ធ ។

សេសបរិសា ពុទ្ធបរិសា រាជបរិសទ្យដ៏សេសបានមកជាពុទ្ធបរិស័ទ ។

សិវិរាជា បន អហមេវ អហោសិំ ចំណែកព្រះបាទសិវិរាជ បានមកជាតថាគត ដូច្នេះឯង ។

ចប់ សិវិជាតក ។

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក វីសតិនិបាត បិដកលេខ ៦០ ទំព័រ ៧៤)

ដោយ ខេមរ អភិធម្មាវតារ

## កំណាព្យឆព្វណ្ណរង្សីពណ៌ខៀវ

*រស្មីពណ៌ខៀវនោះណា កាលភ្នៀលនេត្រាទ្រង់ដោយចិត្តកាត់*
*ឱ្យទានដល់ឥន្ទព្រាហ្មណ៍ពិត កាលនៅជាក្សត្រនាមស្រីពិពស្ត្រ ។*

### ម្យ៉ាងទៀតពោលថា

*ពណ៌ខៀវកាលភ្នៀលព្រះនេត្រា ឲ្យឥន្ទព្រាហ្មណ៍ណាកាលជាក្សត្រ*

*នាមស្រីពិពស្ត្រចង់សម្រេច ឲ្យបានសារពេជ្រសាស្តាចារ្យ ។*





